អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧

# សេចក្តីប្រកាសព័ត៌មាន
## ការបញ្ចប់សវនាការស្តាប់ការធ្វើសេចក្តីសន្និដ្ឋាន
## បិទបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២

នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) បានបិទបញ្ចប់សវនាការស្តាប់ការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ ដែលមានរយៈពេល ៩ ថ្ងៃ ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។ នាពេលនេះ ចៅក្រមនៃអង្គជំនុំជម្រះថយទៅពិភាក្សាដើម្បីចេញសាលក្រម។

សវនាការដេញដោលពិនិត្យភ័ស្តុតាងបានចាប់ផ្តើមដោយការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥ និងបានបញ្ចប់នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៧។ ការជំនុំជម្រះ រួមទាំងការស្តាប់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលផង មានរយៈពេលសរុបចំនួន ២៨៣ ថ្ងៃ។

ក្នុងអំឡុងពេលសវនាការនេះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មពីបុគ្គលសរុបចំនួន ១៨៥ នាក់ ក្នុងនោះមានសាក្សីបញ្ជាក់អង្គហេតុចំនួន ១១៤ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៣ នាក់ និងអ្នកជំនាញចំនួន ៨ នាក់។

សវនាការនេះមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសាធារណជន ដោយមានសាធារណជនចូលរួមស្តាប់ និងតាមដានសវនាការនេះដោយផ្ទាល់ សរុបចំនួន ៨២ ៧៨០ នាក់។

ជនជាប់ចោទដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ មាន នួន ជា ដែលជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និង ខៀវ សំផន ជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។ បទចោទនៅក្នុងសំណុំរឿង ០០២/០២ គឺឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់លើអង្គហេតុដូចតទៅ ៖ ការដ្ឋានការងារ និងសហករណ៍ (សហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់ ១ មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះ

កំពង់ឆ្នាំង) មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស (មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល) អំពើប្រល័យពូជសាសន៍ទៅលើប្រជាជនចាម និងវៀតណាម ការប្រព្រឹត្តិចំពោះពុទ្ធសាសនិកជន និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងការរៀបអាពាហ៍ពិពាហ៍នៅទូទាំងប្រទេស។ អង្គជំនុំជម្រះក៏បានបើកសវនាការដេញដោលពិនិត្យភ័ស្តុតាងលើការចោទប្រកាន់អំពីលក្ខណៈនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម តួនាទីរបស់ជនជាប់ចោទនៅក្នុងរដ្ឋាភិបាល រួមទាំងភ័ស្តុតាងស្តីពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

អង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ជូននូវព័ត៌មានបន្ថែមទៀតអំពីកាលបរិច្ឆេទនៃការចេញសាលក្រមនៃសំណុំរឿងនេះ នាពេលវេលាសមស្របខាងមុខ។


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោកស្រី **ហាយ៉ាត អាប៊ូ-សាឡេះ**
មន្ត្រីទំនាក់ទំនងច្បាប់
ទូរស័ព្ទដៃ៖ +៨៥៥(0) ១២ ៤៨៨ ៩៣៦
អ៊ីម៉ែល៖ abusaleh@un.org

លោក **នេត្រ ភក្ត្រា**
មន្ត្រីអ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ៖ +៨៥៥(0) ១២ ៤៨៨ ១៥៦
អ៊ីម៉ែល៖ neth.pheaktra@eccc.gov.kh